A

អង្គការសហប្រជាជាតិ

មហាសន្និបាត

ចែកចាយ៖ ទូទៅ
លេខ៖ A / RES /៥១/៥៩
២៨ មករា ១៩៩៧

សម័យប្រជុំលើកទីហាសិបមួយ
របៀបវារៈចំណុច១០១

# សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត

[*លើរបាយការណ៍របស់គណៈកម្មាធិការទីបី* )A /៥១/៦១០)]

## ៥១/៥៩. សកម្មភាពប្រឆាំងអំពើពុករលួយ

*មហាសន្និបាត*

*ដោយមានកង្វល់* អំពីភាពធ្ងន់ធ្ងរនៃបញ្ហាដែលបង្កឡើងដោយអំពើពុករលួយ ដែលអាចធ្វើឲ្យគ្រោះថ្នាក់ដល់ស្ថិរភាពនិងសន្តិសុខសង្គម ធ្វើឲ្យខូចតម្លៃនៃលទ្ធិប្រជាធិបតេយ្យនិងសីលធម៌ និងធ្វើឲ្យអន្តរាយដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងនយោបាយ

*ដោយមានកង្វល់ផងដែរ* អំពីទំនាក់ទំនងគ្នារវាងអំពើពុករលួយ និងទម្រង់ដទៃទៀតនៃអំពើល្មើស ជាពិសេសឧក្រិដ្ឋកម្មដែលមានការចាត់តាំង និងបទល្មើសសេដ្ឋកិច្ច រួមទាំងការលាងលុយផងដែរ

*ដោយជឿជាក់*ថា ដោយសារតែអំពើពុករលួយ គឺជាបាតុភូតមួយដែលបច្ចុប្បន្នមានចរិតលក្ខណៈឆ្លងដែន និងប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ចទាំងអស់ ដូច្នេះហើយទើបកិច្ចសហប្រតិបត្តិការអន្តរជាតិ ត្រូវបង្ការទប់ស្កាត់ និងត្រួតពិនិត្យអំពើពុករលួយជាការចាំបាច់

*ដោយជឿជាក់ផងដែរ* អំពីសេចក្តីត្រូវការផ្តល់តាមការស្នើសុំ នូវជំនួយបច្ចេកទេស បង្កើតឡើងដើម្បីធ្វើឲ្យប្រសើរដល់ប្រព័ន្ធគ្រប់គ្រងសាធារណៈ និងដើម្បីបង្កើនគណនេយ្យភាព និងតម្លាភាព

*ដោយរំលឹកឡើងវិញ* អំពីអនុសញ្ញាអន្តរអាមេរិកប្រឆាំងនឹងអំពើពុករលួយ[1] ដែលបានអនុម័តដោយអង្គការនៃបណ្តារដ្ឋទ្វីបអាមេរិក (OAS) នាសន្និសីទឯកទេសសម្រាប់ការពិចារណាលើសេចក្តីព្រាងអនុសញ្ញាអន្តរអាមេរិកប្រឆាំងអំពើពុករលួយ ដែលប្រារព្ធធ្វើនៅទីក្រុងការ៉ាកាស់ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៦

*ដោយរំលឹកឡើងវិញផងដែរ* ពីសេចក្តីសម្រេចរបស់ខ្លួនលេខ៤៥/១២១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០ និងលេខ៤៦/១៥២ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩១ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម លេខ១៩៩២/២២ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩២, លេខ១៩៩៣/៣២ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៣ និងលេខ១៩៩៤/១៩ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៤

*ដោយរំលឹកឡើងវិញជាពិសេស* ពីសេចក្តីសម្រេចរបស់ខ្លួនលេខ៥០/២២៥ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៦ ដែលបានអនុម័តនាសម័យប្រជុំបន្តរបស់ខ្លួន ស្តីពីរដ្ឋបាលសាធារណៈ និងការអភិវឌ្ឍ។

*ដោយរំលឹកឡើងវិញ* ពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម លេខ១៩៩៥/១៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីវិធានការប្រឆាំងអំពើពុករលួយ

*ដោយរំលឹកឡើងវិញផងដែរ* ពីការងារដែលបានអនុវត្តដោយអង្គការអន្តរជាតិ និងអង្គការតំបន់ផ្សេងទៀតក្នុងវិស័យនេះ រួមទាំងសកម្មភាពរបស់ក្រុមប្រឹក្សាអឺរ៉ុប សហភាពអឺរ៉ុប អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ និងអង្គការនៃបណ្តារដ្ឋទ្វីបអាមេរិក(OAS)

១. *ដោយកត់សំគាល់* អំពីរបាយការណ៍របស់អគ្គលេខាធិការស្តីពីវិធានការប្រឆាំងអំពើពុករលួយ[2] ដែលបានដាក់ជូនគណៈកម្មការបង្ការឧក្រិដ្ឋកម្ម និងយុត្តិធម៌ព្រហ្មទណ្ឌ នាសម័យប្រជុំលើកទីប្រាំរបស់ខ្លួន

២. *អនុម័ត* ក្រមសីលធម៌អន្តរជាតិសម្រាប់មន្ត្រីសាធារណៈ ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ និងស្នើដាក់ក្រមសីលធម៌នេះដល់រដ្ឋសមាជិក ទុកជាឧបករណ៍មួយសម្រាប់ណែនាំដល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនប្រឆាំងនឹងអំពើពុករលួយ

---

1 See E/1996/99.

2 E/CN.15/1996/5

៣. *ស្នើ* អគ្គលេខាធិការផ្សព្វផ្សាយក្រមសីលធម៌អន្តរជាតិនេះដល់រដ្ឋទាំងអស់ និងបញ្ចូលក្រមសីលធម៌នេះទៅក្នុងសៀវភៅណែនាំស្តីពីវិធានការជាក់ស្តែងប្រឆាំងអំពើពុករលួយ[3] ដែលនឹងត្រូវបានពិនិត្យឡើងវិញ និងពង្រីកបន្ថែម អនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម លេខ១៩៩៥/១៤ សំដៅដល់ការផ្តល់ឧបករណ៍ទាំងនេះដល់រដ្ឋនានា នៅក្នុងបរិបទនៃសេវាកម្មប្រឹក្សាយោបល់ ការបណ្តុះបណ្តាល ព្រមទាំងសកម្មភាពទាក់ទងនឹងជំនួយបច្ចេកទេស

៤. *ស្នើផងដែរ* ឲ្យអគ្គលេខាធិការបន្តប្រមូលព័ត៌មាន និងអត្ថបទច្បាប់និងបទដ្ឋានគតិយុត្តពីរដ្ឋនានា និងអង្គការអន្តររដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងបរិបទនៃការសិក្សាបន្តរបស់ខ្លួនអំពីបញ្ហាពុករលួយ

៥. *ស្នើបន្ថែម* ដល់អគ្គលេខាធិការ ក្នុងការពិគ្រោះយោបល់ជាមួយរដ្ឋនានា អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនានា ព្រមទាំងសហការជាមួយស្ថាប័នផ្សេងៗទៀតដែលរួមមានបណ្តាញកម្មវិធីបង្ការឧក្រិដ្ឋកម្ម និងយុត្តិធម៌ព្រហ្មទណ្ឌរបស់អង្គការសហប្រជាជាតិ ដើម្បីតាក់តែងឲ្យបានលម្អិតអំពីផែនការអនុវត្តន៍ ហើយដាក់ផែនការនេះជូនទៅគណៈកម្មការបង្ការឧក្រិដ្ឋកម្ម និងយុត្តិធម៌ព្រហ្មទណ្ឌ នាសម័យប្រជុំលើកទីប្រាំមួយរបស់ខ្លួន ជាមួយនឹងរបាយការណ៍របស់លោកអគ្គលេខាធិការ ដែលត្រូវបញ្ជូន ស្របតាមសេចក្តីសម្រេចលេខ១៩៩៥/១៤ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម

៦. *ជម្រុញ* ឲ្យរដ្ឋនានា អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ក៏ដូចជាស្ថាប័នផ្សេងៗទៀត ដែលរួមមានបណ្តាញកម្មវិធីបង្ការឧក្រិដ្ឋកម្ម និងយុត្តិធម៌ព្រហ្មទណ្ឌរបស់អង្គការសហប្រជាជាតិ ដើម្បីពង្រឹងការគាំទ្រយ៉ាងពេញទំហឹងរបស់ខ្លួន ដល់លោកអគ្គលេខាធិការ ក្នុងការតាក់តែងឲ្យបានលម្អិតអំពីផែនការអនុវត្តន៍ និងក្នុងការអនុវត្តកថាខណ្ឌទី៤ ខាងលើ

៧. *ស្នើឲ្យ* រដ្ឋសមាជិកពិចារណាដោយប្រុងប្រយ័ត្ន អំពីបញ្ហាទាំងឡាយដែលបង្កឡើងដោយអំពើពុករលួយដែលមានចរិតលក្ខណៈជាអន្តរជាតិជាពិសេសទាក់ទិននឹងសកម្មភាពសេដ្ឋកិច្ចអន្តរជាតិដែលបានអនុវត្តដោយគ្រឹះស្ថានសាជីវកម្មផ្សេងៗ និងសិក្សាអំពីវិធានការសមស្របតាមច្បាប់និងតាមបទដ្ឋានគតិយុត្តដើម្បីធានាពីតម្លាភាព និងសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុ និងកិច្ចការជំនួញដែលអនុវត្តដោយគ្រឹះស្ថានសាជីវកម្មបែបនេះ

---

[3] International Review of Criminal Policy, Nos. 41 and 42 (United Nations publication, Sales No. E.93.IV.4)

៨. *ស្នើឲ្យ* អគ្គលេខាធិការ ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់លោក ដើម្បីសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពផ្សេងទៀតរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធដទៃទៀត និងដើម្បីសម្របសម្រួលឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតដល់សកម្មភាពអនុវត្តក្នុងវិស័យនេះ

៩. *ស្នើផងដែរ* ឲ្យអគ្គលេខាធិការ ដោយផ្អែកតាមភាពអាចរកបាននៃធនធានថវិការបន្ថែមដើម្បីផ្តល់សេវាប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសបន្ថែមដល់រដ្ឋសមាជិក តាមការស្នើសុំរបស់ពួកគេ ជាពិសេសក្នុងការតាក់តែងសេចក្តីលម្អិតអំពីយុទ្ធសាស្រ្តជាតិ ការតាក់តែងសេចក្តីលម្អិត ឬការកែលំអវិធានការច្បាប់ និងវិធានក្រោមច្បាប់ ការបង្កើត ឬការពង្រឹងសមត្ថភាពជាតិ ដើម្បីបង្ការទប់ស្កាត់និងគ្រប់គ្រងអំពើពុករលួយ ក៏ដូចជាក្នុងការបណ្តុះបណ្តាល និងបង្កើនជំនាញរបស់បុគ្គលិកពាក់ព័ន្ធ

១០. *អំពាវនាវ* ដល់រដ្ឋនានា អង្គការអន្តរជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីផ្តល់ជូនអគ្គលេខាធិការនូវការគាំទ្រ និងការជួយជ្រោមជ្រែងរបស់ខ្លួនយ៉ាងពេញទំហឹង ក្នុងការអនុវត្តសេចក្តីសម្រេចនេះ

១១. *ស្នើ* ឲ្យគណៈកម្មការបង្ការឧក្រិដ្ឋកម្ម និងយុត្តិធម៌ព្រហ្មទណ្ឌ រក្សាបញ្ហានៃវិធានការប្រឆាំងអំពើពុករលួយ ឲ្យស្ថិតក្រោមការត្រួតពិនិត្យជាប្រចាំ។

A/RES/51/59

<u>កិច្ចប្រជុំពេញអង្គលើកទី ៨២</u>

<u>១២ ធ្នូ ១៩៩៦</u>

/...

<u>ឧបសម្ព័ន្ធ</u>

# ក្រមសីលធម៌អន្តរជាតិសម្រាប់មន្ត្រីសាធារណៈ

## I. *គោលការណ៍ទូទៅ*

១. ការិយាល័យសាធារណៈដូចបានកំណត់ដោយច្បាប់ជាតិ គឺជាមុខតំណែងមួយដែលមានទំនុកចិត្ត សំដៅដល់ភារកិច្ចមួយត្រូវបំពេញបម្រើឲ្យផលប្រយោជន៍សាធារណៈ។ ដូច្នេះ ភក្តីភាពខ្ពស់បំផុតរបស់មន្ត្រីសាធារណៈ ត្រូវតែដើម្បីផលប្រយោជន៍សាធារណៈនៃប្រទេសរបស់ខ្លួន ដូចបានបង្ហាញឲ្យឃើញ តាមរយៈស្ថាប័នប្រជាធិបតេយ្យនានារបស់រដ្ឋាភិបាល។

២. មន្ត្រីសាធារណៈត្រូវធានាថា ពួកគេបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងដោយសុចរិតភាព អនុលោមតាមច្បាប់ ឬគោលនយោបាយរដ្ឋបាល។ ពួកគេត្រូវប្រកាន់ខ្ជាប់ គ្រប់ពេលវេលា ធ្វើឲ្យប្រាកដថា ធនធានសាធារណៈ ដែលពួកគេទទួលខុសត្រូវ ត្រូវបានគ្រប់គ្រង ក្នុងលក្ខណៈមួយដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលបំផុត។

៣. មន្ត្រីសាធារណៈ ត្រូវយកចិត្តទុកដាក់ ត្រឹមត្រូវ និងមិនលំអៀង ក្នុងការអនុវត្តមុខងាររបស់ខ្លួន ជាពិសេសក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយសាធារណជន។ នៅពេលណាក៏ដោយ ពួកគេមិនត្រូវប្រព្រឹត្ត ដោយឈរលើការស្រលាញ់ស្អប់ដោយមិនត្រឹមត្រូវណាមួយទៅលើក្រុម ឬបុគ្គលណាមួយ ឬរើសអើងមិនសមស្របចំពោះក្រុម ឬបុគ្គលណាមួយទេ ឬពុំនោះទេ មិនរំលោភអំណាច និងសិទ្ធិដែលបានផ្តល់ឲ្យខ្លួននោះឡើយ។

## II. *ទំនាស់ផលប្រយោជន៍ និងការប្តឹងដិតចិត្ត*

៤. មន្ត្រីសាធារណៈ មិនត្រូវប្រើសិទ្ធិអំណាចផ្លូវការរបស់ខ្លួន ដើម្បីទាញយកប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬផលប្រយោជន៍ហិរញ្ញវត្ថុសម្រាប់គ្រួសារខ្លួនដោយមិនត្រឹមត្រូវនោះឡើយ។ ពួកគេមិនត្រូវចូលរួម ក្នុងកិច្ចការជំនួញណាមួយ ទទួលបានតួនាទី ឬមុខងារណាមួយ ឬមានផលប្រយោជន៍ហិរញ្ញវត្ថុពាណិជ្ជកម្ម ឬផលប្រយោជន៍ដែលអាចប្រៀបធៀបផ្សេងទៀត ដែលមានវិសមិតភាពជាមួយនឹងការិយាល័យ មុខតំណែង និងភារកិច្ចរបស់ខ្លួន ឬក៏បំពេញមុខងារទាំងនោះឡើយ។

៥- មន្ត្រីសាធារណៈ ទៅតាមកម្រិតតួនាទីភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ ឬគោលនយោបាយរដ្ឋបាល ត្រូវប្រកាសពីសកម្មភាព ឬផលប្រយោជន៍ជំនួញ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុដែលទទួលបានចំណូលហិរញ្ញវត្ថុ ដែលអាចនាំឲ្យមានទំនាស់ផលប្រយោជន៍។ ក្នុងស្ថានភាពនៃទំនាស់ផលប្រយោជន៍ ដែលអាចមាន ឬដែលមើលឃើញ រវាងភារកិច្ច និងផលប្រយោជន៍ឯកជនរបស់មន្ត្រីសាធារណៈ ពួកគេត្រូវគោរពតាមវិធានការដែលបានកំណត់ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ទំនាស់ផលប្រយោជន៍បែបនេះ។

៦. មន្ត្រីសាធារណៈ ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវប្រើប្រាស់ដោយមិនត្រឹមត្រូវនូវលុយកាក់សាធារណៈ អចលនទ្រព្យ សេវាកម្ម ឬព័ត៌មានដែលទទួលបាន ក្នុងការអនុវត្ត ឬជាលទ្ធផលនៃការបំពេញតួនាទីភារកិច្ចផ្លូវការរបស់ខ្លួន សម្រាប់សកម្មភាពដែលមិនទាក់ទងនឹងការងារផ្លូវការរបស់ខ្លួនឡើយ។

៧. មន្ត្រីសាធារណៈត្រូវអនុវត្តតាមវិធានការដែលបានកំណត់ដោយច្បាប់ ឬគោលនយោបាយរដ្ឋបាល ដើម្បីឲ្យពួកគេនឹងមិនយកផលប្រយោជន៍មិនត្រឹមត្រូវពីមុខតំណែងកន្លងមករបស់ខ្លួន បន្ទាប់ពីការចាកចេញពីមុខតំណែងផ្លូវការរបស់ខ្លួននោះឡើយ។

## III. *ការប្រកាសទ្រព្យសម្បត្តិ*

៨. យោងតាមតួនាទីភារកិច្ចរៀងខ្លួន និងតាមការអនុញ្ញាត ឬតម្រូវដោយច្បាប់ និងគោលនយោបាយរដ្ឋបាល មន្ត្រីសាធារណៈត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវនានា ដើម្បីប្រកាស ឬបង្ហាញឲ្យដឹងពីទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងបំណុល ប្រសិនជាអាចធ្វើទៅបាន រួមទាំងទ្រព្យសម្បត្តិរបស់សហព័ទ្ធ និង/ឬ ទ្រព្យសម្បត្តិរបស់អ្នករស់នៅក្នុងបន្ទុករបស់ខ្លួនផងដែរ។

## IV. *ការទទួលយកអំណោយ ឬសេចក្ដីពេញចិត្តផ្សេងទៀត*

៩. មន្ត្រីសាធារណៈមិនត្រូវរែអង្គាស ឬទទួលដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយណាមួយ ឬសេចក្តីពេញចិត្តដទៃទៀតដែលអាចមានឥទ្ធិពលដល់ការអនុវត្តមុខងាររបស់ខ្លួន ការបំពេញភារកិច្ចរបស់ខ្លួន ឬការវិនិច្ឆ័យរបស់ខ្លួនឡើយ។

## V. ព័ត៌មានសម្ងាត់

១០. បញ្ហាដែលមានចរិតលក្ខណៈជាការសម្ងាត់ ស្ថិតក្នុងការកាន់កាប់របស់មន្ត្រីសាធារណៈ ត្រូវរក្សាទុកជាការសម្ងាត់ លុះត្រាតែច្បាប់ជាតិ ការបំពេញភារកិច្ច ឬសេចក្តីត្រូវការផ្នែកយុត្តិធម៌ ទាមទារដាច់ខាតត្រូវធ្វើផ្សេងពីនេះ។ ការរឹតត្បិតបែបនេះ ក៏ត្រូវអនុវត្តផងដែរ ក្រោយពីការឈប់បម្រើការងារ។

## VI. សកម្មភាពនយោបាយ

១១. សកម្មភាពនយោបាយ ឬសកម្មភាពផ្សេងទៀតរបស់មន្ត្រីសាធារណៈ នៅក្រៅវិសាលភាពការងាររបស់ខ្លួន អនុលោមតាមច្បាប់ និងគោលនយោបាយរដ្ឋបាល មិនត្រូវជាអាទិ៍ធ្វើឲ្យខូចខាតដល់ទំនុកចិត្តជាសាធារណៈ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយមិនលំអៀងនោះឡើយ។